ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការនិងសាសនា

លេខ: ១៨/២៤ ក.ធ.ស

# សារាចរណែនាំ

## ស្តីពី

## ការប្រឡងវិញ្ញាបនបត្រធម្មវិន័យថ្នាក់ ត្រី ទោ ឯក

**យោង៖** - អនុក្រឹត្យលេខ ១៥៤ អនក្រ.បក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការនិងសាសនា

- ប្រកាសលេខ ៦៥៩/១១ ក.ធ.ស.ប្រក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១១ ស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់ការិយាល័យថ្នាក់កណ្តាល អង្គភាពមូលដ្ឋាន និងការិយាល័យចំណុះផ្នែកនានាក្រោមឱវាទ
- ប្រកាសលេខ ០០១ ក.ធ.ស/ប្រក ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃការប្រឡងវិញ្ញាបនបត្រធម្មវិន័យថ្នាក់ ត្រី ទោ ឯក
- លិខិតលេខ ១៨៣/២៤ អ.ព.ស.ជ. ចុះថ្ងៃសុក្រ ១០រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២៤ ស្តីពីផែនការប្រឡងសម្រាប់ឆ្នាំសិក្សា២០២៤-២០២៥

ដើម្បីរៀបចំការប្រឡងវិញ្ញាបនបត្រធម្មវិន័យថ្នាក់ **ត្រី ទោ ឯក** ឱ្យមានលក្ខណៈល្អប្រសើរ ក្រសួងធម្មការនិងសាសនា សូមជូនដំណឹងដល់លោកប្រធានមន្ទីរធម្មការនិងសាសនា គ្រប់រាជធានី ខេត្ត ឱ្យបានជ្រាបថា ក្រសួងធម្មការនិងសាសនា នឹងរៀបចំការប្រឡងវិញ្ញាបនបត្រធម្មវិន័យថ្នាក់ **ត្រី ទោ ឯក** សម្រាប់ដំណាច់ឆ្នាំសិក្សា២០២៤-២០២៥ តាមលក្ខខណ្ឌដូចខាងក្រោម ៖

១-កាលបរិច្ឆេទនៃការប្រឡង: **ថ្ងៃអាទិត្យ ៧កើត ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៥ ខែមករា ឆ្នាំ២០២៥។**

២-ប្រធានមន្ទីរធម្មការនិងសាសនារាជធានី ខេត្ត ត្រូវផ្តល់ស្ថិតិសាលាធម្មវិន័យ ចំនួនបន្ទប់ និងចំនួនបេក្ខសមណៈ បេក្ខជន ដែលបានដាក់ពាក្យសុំប្រឡងពិតប្រាកដនិងរូបថតបច្ចុប្បន្នភាព ៤ X ៦ ចំនួនពីរសន្លឹកសម្រាប់បេក្ខភាពមួយរូបៗ បព្វជិតត្រូវតែជារូបថតបរិមណ្ឌលដោយឃ្លុំចីពរចំពីមុខឱ្យច្បាស់ ឯគ្រហស្ថត្រូវពាក់អាវសតាមបរិបទនៃវ័យទាំងបី (បឋមវ័យ មជ្ឈិមវ័យ បច្ឆិមវ័យ ) រួចបញ្ជូនមកអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិឱ្យបានមុន**ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៤** ដើម្បីងាយស្រួលត្រៀមរៀបចំសំណុំបែបបទ និងឯកសារផ្សេងៗ ដែលទាក់ទងនឹងការប្រឡងឱ្យបានទាន់ពេលវេលា។

៣-ប្រធានមន្ទីរធម្មការនិងសាសនារាជធានី ខេត្ត ត្រូវធ្វើលិខិតបង្គាប់ការ គណៈមេប្រយោគ និងបញ្ជីរាយនាមបេក្ខសមណៈ បេក្ខជន ប្រឡងគ្រប់មណ្ឌលហើយបញ្ជូនមួយមុខមួយច្បាប់មកអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិឱ្យបានមុន**ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៤** ជាកំហិត។



អាសយដ្ឋាន៖ វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរសព្ទ៖ (៨៥៥-២៣) ៧២២ ៦៩៩
អ៊ីម៉ែល៖ mocargovkh@gmail.com
គេហទំព័រ៖ www.mocar.gov.kh

៤-ប្រធានមន្ទីរធម្មការនិងសាសនារាជធានី ខេត្ត ត្រូវបើកឱកាសឱ្យបានទូលំទូលាយដល់បេក្ខសមណៈ បេក្ខជន ដូនជី តាជី មកពីគ្រប់មជ្ឈដ្ឋានបានដាក់ពាក្យប្រឡងតាមការកំណត់ ដែលមានចែងក្នុងសារាចរនេះ។ ប៉ុន្តែអនុញ្ញាតឱ្យប្រឡងតាមលំដាប់លំដោយនៃថ្នាក់នីមួយៗ គឺបេក្ខសមណៈ បេក្ខជន អាចសុំសិទ្ធិប្រឡងថ្នាក់ទោបាន លុះត្រាតែមានវិញ្ញាបនបត្រថ្នាក់ត្រី ប្រឡងថ្នាក់ឯកបាន លុះត្រាតែមានវិញ្ញាបនបត្រថ្នាក់ទោ។ ក្នុងករណីពុំមានវិញ្ញាបនបត្រពិតសម្រាប់ថ្នាក់ ត្រី ទោ បេក្ខសមណៈ បេក្ខជននោះ អាចភ្ជាប់គោលបញ្ជីដែលជាលទ្ធផលប្រឡងជាប់ស្ពាពរួចហើយ។

៥-ប្រធានមន្ទីរធម្មការនិងសាសនារាជធានី ខេត្ត ត្រូវចាត់តំណាងឱ្យមកទទួលយកក្រដាសការិយកិច្ចនិងឯកសារពាក់ព័ន្ធឱ្យបានមុនថ្ងៃប្រឡងចំនួន២០ថ្ងៃ។

៦-វិញ្ញាសា ថិរវេលា ពិន្ទុនៃការប្រឡងវិញ្ញាបនបត្រធម្មវិន័យថ្នាក់ **ត្រី ទោ ឯក** នឹងត្រូវបានកំណត់ដូចខាងក្រោម ៖

| | |
|---|---|
| **ក- វិញ្ញាសាទី១ ប្រជុំកងធម៌** | **រយៈពេល ២ ម៉ោង ពិន្ទុពី ០ ដល់ ១០** |
| **ខ- វិញ្ញាសាទី២ ពុទ្ធប្បវត្តិ** | **រយៈពេល ២ ម៉ោង ពិន្ទុពី ០ ដល់ ១០** |
| **គ- វិញ្ញាសាទី៣ ព្រះវិន័យ** | **រយៈពេល ២ ម៉ោង ពិន្ទុពី ០ ដល់ ១០** |
| **ឃ-វិញ្ញាសាទី៤ សាសនសុភាសិត** | **រយៈពេល ២ ម៉ោង ពិន្ទុពី ០ ដល់ ១០** |

វិញ្ញាសានីមួយៗនឹងត្រូវបានពិន្ទុសូន្យ ចំពោះបេក្ខសមណៈ បេក្ខជនអវត្តមាន ឬមិនប្រគល់កិច្ចការដល់គណៈមេប្រយោគ។ ដោយឡែក បេក្ខសមណៈ បេក្ខជន ដែលប្រឡងបានពិន្ទុសរុបក្រោម ២០ ពិន្ទុចុះមកចាត់ទុកប្រឡងធ្លាក់។

៧-មណ្ឌលដែលត្រូវប្រឡងមានចំនួន២៥ រាជធានី ខេត្តគឺ ៖

| | | | |
|---|---|---|---|
| **១-រាជធានីភ្នំពេញ** | **២-ខេត្តកែប** | **៣-ខេត្តព្រះសីហនុ** | **៤-ខេត្តកោះកុង** |
| **៥-ខេត្តក្រចេះ** | **៦-ខេត្តប៉ៃលិន** | **៧-ខេត្តឧត្តរមានជ័យ** | **៨-ខេត្តស្ទឹងត្រែង** |
| **៩-ខេត្តព្រះវិហារ** | **១០-ខេត្តមណ្ឌលគិរី** | **១១-ខេត្តរតនគិរី** | **១២-ខេត្តពោធិ៍សាត់** |
| **១៣-ខេត្តកណ្ដាល** | **១៤-ខេត្តតាកែវ** | **១៥-ខេត្តកំពត** | **១៦-ខេត្តស្វាយរៀង** |
| **១៧-ខេត្តកំពង់ឆ្នាំង** | **១៨-ខេត្តត្បូងឃ្មុំ** | **១៩-ខេត្តបាត់ដំបង** | **២០-ខេត្តកំពង់ធំ** |
| **២១-ខេត្តសៀមរាប** | **២២-ខេត្តកំពង់ស្ពឺ** | **២៣-ខេត្តកំពង់ចាម** | **២៤-ខេត្តព្រៃវែង** |
| **២៥-ខេត្តបន្ទាយមានជ័យ។** | | | |

ប៉ុន្តែនៅរាជធានី ខេត្ត ដែលមានមណ្ឌលច្រើនអាចបង្កើតជាមណ្ឌលប្រឡងបាន លុះត្រាតែមានសមណសិស្ស សិស្ស ចាប់ពី១០០រូបឡើងទៅ។ ចំពោះរាជធានី ខេត្ត ដែលមានតែមួយមណ្ឌល (មិនកំណត់សមណសិស្ស សិស្ស ) អាចបង្កើតមណ្ឌលប្រឡងបានធម្មតា។

៨-ចំពោះរាជធានី ខេត្ត ដែលមានមណ្ឌលប្រឡងលើសពីមួយ មន្ទីរធម្មការនិងសាសនារាជធានី ខេត្តនោះ ត្រូវរៀបចំឱ្យមានមណ្ឌលកំណែតែមួយកន្លែងប៉ុណ្ណោះ។

៩-ប្រធានមន្ទីរធម្មការនិងសាសនារាជធានី ខេត្ត ត្រូវផ្ញើសំណុំបែបបទពេលប្រឡងចប់និងកែរួចមានដូចខាងក្រោម ៖

ក-កំណត់ហេតុសរុបរបស់មន្ទីរធម្មការនិងសាសនារាជធានី ខេត្ត ដែលប្រឡងជាប់និងធ្លាក់ពិតប្រាកដ។

ខ-កំណត់ហេតុសរុបរបស់មណ្ឌលនីមួយៗស្តីពីលទ្ធផលជាប់និងធ្លាក់របស់បេក្ខសមណ: បេក្ខជន។

គ-បញ្ជីស្រង់ពិន្ទុ បញ្ចូលឈ្មោះបេក្ខសមណ: បេក្ខជនជាប់និងធ្លាក់។

ឃ-បញ្ជីស្រង់ឈ្មោះ បេក្ខសមណ: បេក្ខជន គូសជាប់ ធ្លាក់ ឱ្យបានច្បាស់ដោយមានភ្ជាប់ជាមួយនូវគំរូស្រង់ពិន្ទុនិងគំរូជាប់ ធ្លាក់ ឱ្យរួចជាស្រេចសម្រាប់មណ្ឌលនីមួយៗ ដើម្បីជួយសម្រួលការងារឱ្យបានឆាប់រហ័ស។

ង-បញ្ជីស្រង់ពិន្ទុនិងបញ្ជីសម្រាប់គូស (ជាប់ឬធ្លាក់) ត្រូវបញ្ជូនមកអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិយ៉ាងយូរបំផុតត្រឹម**ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២៥** បើមិនដូច្នោះ ក្រសួងនឹងចាត់ទុកថា មិនបានប្រឡងឡើយ។

សូមលោកប្រធានមន្ទីរធម្មការនិងសាសនារាជធានី ខេត្ត ទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ។

ថ្ងៃព្រហស្បតិ៍ ៩រោច ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៤

**រដ្ឋមន្ត្រី**

ចាយ បូរិន

**កន្លែងទទួល ៖**

-សម្តេចព្រះមហាសង្ឃរាជទាំងពីរគណ:

-គណ:សង្ឃនាយកទាំងពីរគណ:

-ទីស្តីការគណ:រដ្ឋមន្ត្រី

-ក្រសួងមហាផ្ទៃ

-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-ក្រសួងអប់រំ យុវជន និង កីឡា

(ដើម្បីថ្វាយ ជូនជ្រាប)

-រដ្ឋបាលរាជធានី ខេត្ត

-អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ

-មន្ទីរធម្មការនិងសាសនារាជធានី ខេត្ត

-គ្រប់អង្គភាពពាក់ព័ន្ធ

(ដើម្បីសហការអនុវត្ត)

-ឯកសារកាលប្បវត្តិ